**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧៣.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- តាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**មាត្រា១.~**

ត្រូវបានតែងតាំងសមាសភាពសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់ដឹកនាំអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ចំនួន ៥ រូប ដូចមានរាយនាមខាងក្រោម ៖

១- **ឯកឧត្តម ស៊ុំ សន្និសិទ្ធ** តំណាងធនាគារជាតិនៃកម្ពុជា ជាប្រធានក្រុមប្រឹក្សាភិបាលបន្ថែមលើមុខងារបច្ចុប្បន្ន

២- **ឯកឧត្តម ប៉ែន ពេជ្រសាលី** តំណាងក្រសួងយុត្តិធម៌ ជាសមាជិកក្រុមប្រឹក្សាភិបាលបន្ថែមលើមុខងារបច្ចុប្បន្ន

៣- **ឯកឧត្តម ទឹមរ័ត្ន ទិសិដ្ឋ** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកក្រុមប្រឹក្សាភិបាលបន្ថែមលើមុខងារបច្ចុប្បន្ន



www.pheakdeylaw.com

៤- **ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា** តំណាងក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន

៥- **ឯកឧត្តម រស់ សីលវ៉ា** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិកក្រុមប្រឹក្សាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចក្នុងមាត្រា៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com